Australian Government

What's Next?

# ជំនួយសម្រាប់កម្មករផលិតរថយន្ត

*មានជំនួយសម្រាប់ជួយកម្មករចេញពីឧស្សាហកម្មរថយន្តទៅកាន់ការងារថ្មី នៅពេលឧស្សាហកម្មផលិតរថយន្តបិទទ្វានៅប្រទេសអូស្ត្រាលី។*

កម្មវិធីផ្តួចផ្តើមគំនិតក្នុងការបណ្តុះបណ្តាល និងបំណិនបង្កើតឡើងដើម្បីជួយកម្មករពីក្រុមហ៊ុន Holden និង Toyota ។

កម្មវិធីផ្តួចផ្តើមគំនិតក្នុងការបណ្តុះបណ្តាល និងបំណិនបំពេញកម្មវិធីរដ្ឋាភិបាលប្រចាំរដ្ឋសម្រាប់កម្មករចង្វាក់ផ្គត់ផ្គង់ដែលមានសិទ្ធិ ក៏ដូចជាសកម្មភាពមានស្រាប់ដែលអនុវត្តដោយក្រុមហ៊ុន Holden និង Toyota ដើម្បីជួយកម្មករពួកគេឲ្យត្រៀមរួចសម្រាប់ការងារ។

គំនិតផ្តួចផ្តើមគំនិតទាំងអស់នេះមានបំណងជួយកម្មករដែលរងផលប៉ះពាល់ ដែលភាគច្រើនមានបទពិសោធន៍យ៉ាងច្រើន និងមានជំនាញខ្ពស់ដើម្បីឈានរកការងារថ្មី ឱកាសរកស៊ីខ្លួនឯង ឬចូលនិវត្ត។

គំនិតផ្តួចផ្តើមទាំងនេះនឹងជួយកម្មករកសាងបន្ថែមលើបំណិនដែលមានស្រាប់ និងទទួលបានបំណិនថ្មីៗដែលអាចឈានចាប់យកការងារនៅវិស័យផ្សេងទៀត ដូចជាសេវាសុខាភិបាល ទេសចរណ៍ អប់រំ ម្ហូបអាហារ និងកសិកម្ម ហើយនិងផលិតកម្មទំនើបៗ។

ក្រុមហ៊ុន Holden និង Toyota ក្រុមហ៊ុនមួយៗបានផ្តល់ថវិការ ចំនួន $15 លានដល់កម្មវិធីផ្តួចផ្តើមគំនិតក្នុងការបណ្តុះបណ្តាល និងបំណិន។

## តើកម្មករនឹងទទួលបានការគាំទ្រអ្វីខ្លះ?

ការផ្តួចផ្តើមគំនិតទាំងនេះផ្តល់ការគាំទ្រទៅតាម តម្រូវការដោយរួមមាន៖

- ការអប់រំផ្នែកហិរញ្ញវត្ថុ
- សេវាសុខាភិបាល និងសុខមាលភាព
- ព័ត៌មានស្តីពីការងារដែលមានតម្រូវការ
- តំបូន្មានស្តីពីអាជីព ការបណ្តុះបណ្តាល និង ផ្លាស់ប្តូរ
- ការវាយតម្លៃបំណិន និងការទទួលស្គាល់បំណិន
- ការបំណុះបណ្តាល និងការផ្តល់បំណិនទូទៅ (ដូចជាបំណិនទំនាក់ទំនងជាមួយអ្នកដទៃ ឬផ្ទាល់មាត់)
- តំបូន្មានស្តីពីការចាប់ផ្តើមជំនួញ។

## តើកម្មករនឹងអាចទទួលសេវាទាំងនេះ នៅពេលណា?

កម្មករនឹងទទួលបានសេវាទាំងនេះក្នុងអំឡុងពេលពួកគេកំពុងធ្វើការងារបច្ចុប្បន្ននេះ។

សេវាទាំងនេះនឹងអនុវត្តតាមដំណាក់កាលសម្របសម្រួល និងកម្មករទទួលព័ត៌មាននៅពេលសេវាទាំងនេះដាក់ឲ្យប្រើប្រាស់។

សេវាមួយចំនួននឹងមានបន្តសម្រាប់កម្មករ រហូតដល់បន្ទាប់ពីពួកគេចាកចេញពីការងារពួកគេ។

រដ្ឋាភិបាលអូស្ត្រាលីបានសហការជាមួយក្រុមហ៊ុន Holden Toyota ហើយនិងរដ្ឋាភិបាល ការគាំទ្រដោយរលូនដល់កម្មករ។

## ការគាំទ្រសម្រាប់កម្មករក្រុមហ៊ុន Holden និង Toyota

ក្រុមហ៊ុន Holden និង Toyota នឹងផ្តល់សេវាភាគច្រើនដល់កម្មករពួកគេ។

ក្រុមហ៊ុន Toyota បានបង្កើតកម្មវិធីអភិវឌ្ឍន៍ និងសិក្សាដែលតម្រូវទៅតាមបុគ្គលម្នាក់ៗ ដែលស្គាល់ថា 'DRIVE' (វិជ្ជាជីវៈនៃបុគ្គលត្រៀមលក្ខណៈរួចរាល់ និងតាំងចិត្តខ្ពស់ប្រកបដោយថាមពល- Dedicated Ready Individual Vocational Energised)។

ក្រុមហ៊ុន Holden បានបង្កើតមជ្ឈមណ្ឌលផ្លាស់ប្តូរដើម្បីជួយឲ្យកម្មករអាចពិភាក្សាអំពីអាជីពរបស់បុគ្គលម្នាក់ៗ ហើយនិងជម្រើសការបណ្តុះបណ្តាល។

កម្មករអាចទាក់ទងការិយាល័យធនធានមនុស្សនៅតាមតំបន់របស់ពួកគេដើម្បីរកព័ត៌មានបន្ថែម។

## ការគាំទ្រសម្រាប់កម្មករក្រុមហ៊ុន Ford

ក្រុមហ៊ុន Ford អូស្ត្រាលីបានប្រកាសបិទប្រតិបត្តិការផលិតគ្រឿងម៉ាស៊ីន និងរថយន្តរបស់ខ្លួនមុនក្រុមហ៊ុន Holden និង Toyota ។

កម្មករក្រុមហ៊ុន Ford កំពុងទទួលការគាំទ្រផ្នែកបង្កើនបំណិន និងរៀនបំណិនថ្មីតាមរយៈគម្រោងផ្លាស់ប្តូររបស់ក្រុមហ៊ុន Ford ។

រដ្ឋាភិបាលអូស្ត្រាលីបានផ្តល់ថវិកាចំនួន $5 លានដល់ក្រុមហ៊ុន Auto Skills Australia ដើម្បី គាំទ្រការផ្លាស់ប្តូររបស់កម្មករពីការងារសព្វថ្ងៃ ទៅការងារប្រកបដោយអត្ថន័យនៅពេលរោងចក្របិទទ្វារ។

កម្មករអាចទាក់ទងធនធានមនុស្សនៅតាមតំបន់របស់ពួកគេដើម្បីរកព័ត៌មានបន្ថែម។

និយោជិកក្រុមហ៊ុន Ford ដែលត្រូវបានកាត់បន្ថយក៏មានសិទ្ធិទទួលសេវារបស់គម្រោងផ្លាស់ ប្តូររបស់ក្រុមហ៊ុន Ford ដែលផ្តល់ដោយក្រុមហ៊ុន Auto Skills Australia ដែរ។

## ការគាំទ្រសម្រាប់កម្មករចង្វាក់ផ្គត់ផ្គង់នៅអូស្ត្រាលីភាគខាងត្បូង

កម្មករដែលមានសិទ្ធិអាចទទួលកញ្ចប់គាំទ្រពីកម្មវិធីកម្មកររោងចក្ររថយន្តក្នុងការផ្លាស់ប្តូររបស់រដ្ឋាភិបាលអូស្ត្រាលីភាគខាងត្បូង។ សម្រាប់ព័ត៌មានបន្ថែម៖

- អ៊ីម៉េល **workersintransition@sa.gov.au**
- ហៅទូរស័ព្ទមកកាន់លេខ **1800 774 010**
- ចូលទស្សនាវិបសាយថ៍ **www.statedevelopment.sa.gov.au/industry/automotive/awtp**

## ការគាំទ្រសម្រាប់កម្មករចង្វាក់ផ្គត់ផ្គង់នៅរដ្ឋវិចតូរីយ៉ា

កម្មករដែលមានសិទ្ធិអាចទទួលសវាគាំទ្រតាម រយៈមជ្ឈមណ្ឌលការងារ និងបំណិនរបស់រដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា។ សេវារួមមានអាជីពវិជ្ជាជីវៈ និង ការផ្តល់តំបូន្មានពីការបណ្តុះបណ្តាល និងលទ្ធភាពទទួលបន្ថែម

នូវការបណ្តុះបណ្តាល ដែលមានការទទួលស្គាល់តាមរយៈកម្មវិធីធានាបណ្តុះបណ្តាលនៃរដ្ឋវិចតូរីយ៉ា (Victorian Training Guarantee) ។

### មជ្ឈមណ្ឌលការងារ និងបំណិន

- Dandenong (03) 8774 4298
- Chadstone (03) 9564 2755
- Broadmeadows (03) 9041 3893
- Sunshine (03) 9919 9988

សម្រាប់ព័ត៌មានបន្ថែម៖

អ៊ីម៉ែល៖ **auto.industry@edumail.vic.gov.au**

ទស្សនា៖

**http://www.education.vic.gov.au/auto**

## តើមានការគាំទ្រអ្វីនឹងផ្តល់ជូនកម្មករដើម្បីស្វែងរកការងារថ្មី?

ចំនួននិយោជកភាគច្រើននឹងធ្វើដៃគូជាមួយរដ្ឋាភិបាល ក្រុមហ៊ុន Holden Toyota Ford និងក្រុមហ៊ុនចង្វាក់ផ្គត់ផ្គង់ដើម្បីកំណត់ឱកាសការងារ និងជួយរកការងារថ្មីឲ្យកម្មករធ្វើ។

បន្ថែមពីលើកម្មវិធីគាំទ្រដែលបង្ហាញខាងលើ រដ្ឋាភិបាលអូស្ត្រាលីនឹងបន្តផ្តល់ការគាំទ្រដល់ក្រុមហ៊ុន Holden Toyota Ford និងកម្មករចង្វាក់ផ្គត់ផ្គង់ដែលមានសិទ្ធិតាមរយៈកម្មវិធីកែសម្រួលរចនាសម្ព័ន្ធឧស្សាហកម្មរថយន្ត (Automotive Industry Structural Adjustment Programme)។

កម្មវិធីនេះផ្តល់ជំនួយខាង៖

- សរសេរប្រវត្តិរូបរកការងារ
- រៀបចំពាក្យសុំការងារ
- បំណិនសម្ភាសន៍
- រៀនយកសំបុត្រ និងអាជ្ញាប័ណ្ណ

សម្រាប់ព័ត៌មានបន្ថែម សូមទស្សនា៖

**www.whatsnext.employment.gov.au/aisap**

## អំពីមូលនិធិកំណើន(Growth Fund)

កម្មវិធីផ្តួចផ្តើមគំនិតក្នុងការបណ្តុះបណ្តាល និងបំណិនគឺជាធាតុផ្សំរបស់មូលនិធិកំណើននៃរដ្ឋាភិបាលអូស្ត្រាលី ដែលគាំទ្រកម្មករ ក្រុមហ៊ុន និងតំបន់ដែលរងផលប៉ះពាល់ដោយការផ្លាស់ប្តូរក្នុងឧស្សាហកម្មរថយន្តនៃប្រទេសអូស្ត្រាលី។

មូលនិធិកំណើនបង្កើតឡើងដោយរដ្ឋាភិបាលអូស្ត្រាលីដោយមានការគាំទ្រ និងវិភាគទានពីរដ្ឋាភិបាលរដ្ឋវិចតូរីយ៉ា និងរដ្ឋាភិបាលអូស្ត្រាលីភាគខាងត្បូង ក្រុមហ៊ុន Holden និង Toyota ។

សម្រាប់ព័ត៌មានបន្ថែម សូមទស្សនា៖

**www.business.gov.au/GrowthFund**

## ដើម្បីស្វែងរកបន្ថែម សូមទស្សនា

changinglanes.employment.gov.au